ភ្នំពេញ, ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា មានកិត្តិយសជម្រាបជូនសាធារណៈជន អ្នកសារព័ត៌មានជាតិ-អន្តរជាតិ វិទ្យុ ទូរទស្សន៍ តំណាងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងតំណាងអង្គទូតឲ្យបានជ្រាបថា នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤ ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា នឹងរៀបចំកិច្ចពិភាក្សាតុមូលស្តីពី **«ការកំណត់អាណត្តិនាយករដ្ឋមន្ត្រី»**។

សេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញមាត្រា១១៩ថ្មី ដោយបន្ថែមវាក្យខ័ណ្ឌចំនួនមួយ៖....**«វីរជនមួយរូបជាបេក្ខជននាយករដ្ឋមន្ត្រី មិនត្រូវជាបេក្ខជនដែលធ្លាប់កាន់ដំណែងជានាយករដ្ឋមន្ត្រីចំនួនពីរ (០២) អាណត្តិ ឬរយៈពេលដប់ (១០)ឆ្នាំកន្លងមកហើយ»**.......។

កិច្ចពិភាក្សាតុមូលនេះមានគោលបំណងឲ្យអ្នកចូលរួមបញ្ចេញទស្សនៈ និងការយល់ឃើញពាក់ព័ន្ធប្រធានបទនេះ។

កាលបរិច្ឆេទ ៖ ថ្ងៃទី១៩ ខែសីហា ២០១៤
វេលាម៉ោង ៖ ០៨:០០ ព្រឹក
ទីកន្លែង ៖ ភោជនីយដ្ឋានខ្មែរសូរិន
(ផ្ទះលេខ ០៩, ផ្លូវលេខ៥៧, សង្កាត់បឹងកេងកង១, ខណ្ឌចំការមន, រាជធានីភ្នំពេញ)
រៀបចំដោយ ៖ ក្រុមអង្គការសង្គមស៊ីវិល

**វាគ្មិនចូលរួមសំខាន់ៗរួមមាន៖**

- លោកបណ្ឌិត កែម ឡី — អ្នកស្រាវជ្រាវសង្គមឯករាជ្យ
- លោកបណ្ឌិត សុខ ទូច — អ្នកវិភាគនយោបាយឯករាជ្យ
- លោកមេធាវី សុក សំអឿន — ប្រធានក្រុមប្រឹក្សាភិបាលលេខាធិការដ្ឋាន CHRAC
- លោក នី ចរិយា — ប្រធានផ្នែកអង្កេតនៃសមាគម អាដហុក
- លោក គល់ បញ្ញា — នាយប្រតិបត្តិអង្គការ ខុមហ្វ្រែល (អ្នកសម្របសម្រួល)

អាស្រ័យដូចបានជម្រាបជូនខាងលើ យើងខ្ញុំសូមគោរពអញ្ជើញសាធារណៈជន អ្នកសារព័ត៌មានជាតិ-អន្តរជាតិ វិទ្យុ ទូរទស្សន៍ តំណាងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងតំណាងអង្គទូត ចូលរួមក្នុងកិច្ចពិភាក្សា និងយកព័ត៌មានកុំបីខាន៕

ព័ត៌មានបន្ថែមសូមទាក់ទង៖ ០២៣ ៨៨៤ ១៥០ / ០៨៩ ២១ ២១ ១០